# ការណែនាំរបស់ជំនួយការថែទាំ





## ជូនចំពោះអ្នកគ្រប់គ្នាដែលចង់ក្លាយជាជំនួយការថែទាំ


១. តើការងារថែទាំជាអ្វី? 1

២. អំពីការងាររបស់ជំនួយការថែទាំ 5

៣. អំពីស្ថានភាពទូទៅនៃការងារ 7

៤. អំពីខ្លឹមសារនៃការងារជាក់ស្តែង 9


## ឯកសារបទបង្ហាញនៅពេលទទួលយកជំនួយការថែទាំ


អំពីចំណុចប្រុងប្រយ័ត្ននៅកំឡុងពេលធ្វើការ 15

ឧបសម្ព័ន្ធ ឯកសារយោងការងារ
<ឧទាហរណ៍នៃលំហូរក្នុង១ថ្ងៃ> 17

# ជូនចំពោះអ្នកគ្រប់គ្នាដែលចង់ក្លាយជាជំនួយការថែទាំ

អ្នកទាំងអស់គ្នាដែល (មិនមានសញ្ញាបត្រ ប៉ុន្តែមានចំណាប់អារម្មណ៍លើការងារថែទាំ)
តើអ្នកចង់ធ្វើការជាមួយគ្នាក្នុងនាមជា“ ជំនួយការថែទាំ” ឬទេ?
អាស្រ័យទៅតាមទីកន្លែង អាចនឹងត្រូវបានគេហៅថា "អ្នកបម្រុងជួយថែទាំ" ឬ "អ្នកជួយគាំទ្រថែទាំ" ជំនួសឱ្យ "ជំនួយការថែទាំ" ។ ការងារនេះគឺពាក់ព័ន្ធនឹងការងាររបស់អ្នកមើលថែទាំមនុស្សចាស់ ហើយមានលក្ខណៈពិសេសត្រង់ថា អាចចាប់ផ្តើមធ្វើការបានចាប់ពីគ្រប់វ័យ ទោះមិនមានសញ្ញាបត្រក៏ដោយ ក៏អាចចូលរួមធ្វើការក្នុងការងារជំនួយការថែទាំនេះបានដែរ។
សៀវភៅណែនាំនេះគឺមានគោលបំណងចង់ អោយអ្នកដឹងថាតើ“ជំនួយការថែទាំ”គឺជាអ្វី? និងមានបំណងក្លាយជា“ ជំនួយការថែទាំ ”សម្រាប់អ្នកដែលមានចាប់អារម្មណ៍ ចង់ ធ្វើការងារថែទាំ ប៉ុន្តែមានការព្រួយបារម្ភអំពីសម្បទានិងកម្លាំងរាងកាយរបស់ខ្លួន ឬអ្នកដែលស្ទាក់ស្ទើរក្នុងការសិក្សាដើម្បីទទួលបានសញ្ញាបត្រ។

## ១. តើការងារថែទាំជាអ្វី?

ដំបូងយើងនឹងណែនាំប្រភេទនៃសេវាកម្ម កន្លែងពាក់ព័ន្ធ និងមុខរបរ ដើម្បីឱ្យអ្នកស្គាល់ឧស្សាហកម្មថែទាំយូរអង្វែងនៅពេលចូលរួមក្នុងការងារថែទាំរយៈពេលវែង។

### (១) ប្រភេទសេវាកម្មថែទាំ

សេវាកម្មថែទាំនេះមានទម្រង់ផ្សេងៗជាច្រើនដូចជាផ្តល់ជូនអ្នកថែទាំទៅដល់ផ្ទះអតិថិជនដែលកំពុងប្រើសេវាកម្មនេះ ឬអតិថិជនមកទីតាំងយើងផ្ទាល់ហើយយើងផ្តល់សេវាកម្មទៅអតិថិជនផ្ទាល់ជាដើម។
ខាងក្រោមនេះយើងណែនាំប្រភេទនិងខ្លឹមសារនៃសេវាកម្មថែទាំចម្បង។

តារាង : សេវាកម្មចម្បង

| ប្រភេទ | ឈ្មោះសេវាកម្ម/ទីកន្លែង | ខ្លឹមសារ |
|---|---|---|
| សេវាកម្មចូលនៅមណ្ឌល | មណ្ឌលសុខភាពថែទាំមនុស្សចាស់ ( មណ្ឌលមនុស្សចាស់) | គឺជាមណ្ឌលផ្តល់សេវាកម្មប្រចាំថ្ងៃ ដូចជាការស្តារនីតិសម្បទា ថែទាំ វេជ្ជសាស្ត្រ អាហារ ងូតទឹកជាដើម ក្រោមការគ្រប់គ្រងវេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត ដើម្បីឱ្យអ្នកដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយសាររបួសឬមានជម្ងឺផ្សេងៗ អាចវិលត្រឡប់ទៅរកជីវភាពរស់នៅធម្មតានៅក្នុងផ្ទះរបស់ពួកគេវិញ បន្ទាប់ពីចេញពីមន្ទីរពេទ្យ។ |
| | មណ្ឌលសុខុមាលភាពថែទាំមនុស្សចាស់ | ជាទីកន្លែងរស់នៅសម្រាប់មនុស្សចាស់ដែលត្រូវការមើលថែទាំរយៈពេល២៤ម៉ោង ឬការមើលថែទាំនៅផ្ទះមានភាពលំបាកដូចជាក្នុងសភាពគេងលើគ្រែរហូតជាដើម។ |
| | មណ្ឌលប្រភេទមន្ទីរពេទ្យថែទាំសុខភាព | ជាស្ថាប័នវេជ្ជសាស្ត្រមួយដែលផ្តល់សេវាថែទាំបំប៉ន ដល់អ្នកដែលមានជម្ងឺរ៉ាំរ៉ៃហើយត្រូវការការព្យាបាលរយៈពេលវែង។ |
| | គ្លីនិកថែទាំសុខភាព | ជាកន្លែងរស់នៅសម្រាប់អ្នកដែលត្រូវការការថែទាំ និងព្យាបាលសុខភាពរយៈពេលវែង។ |
| សេវាកម្មទៅមកមណ្ឌល | ការទៅមកមណ្ឌលដើម្បីស្តារនីតិកាយសម្បទា (ថែទាំប្រចាំថ្ងៃ) | ប្រើប្រាស់សេវានេះដើម្បីមើលថែសុខភាពមនុស្សចាស់។ យើងធ្វើការព្យាបាលស្តារកាយនីតិសម្បទាអោយបានជាសះស្បើយ ជាមួយអ្នកជំនាញឯកទេស ដូចជាគ្រូពេទ្យព្យាបាលរាងកាយនិងគ្រូពេទ្យព្យាបាលចលនា ដើម្បីជួយជីវភាពរស់នៅមានភាពម្ចាស់ការ និងថែរក្សាប្រព័ន្ធសរីរាង្គកាយអោយជាសះស្បើយឡើងវិញ។ |
| | ការថែទាំបំប៉នសុខភាពនៅមណ្ឌលរយៈពេលខ្លី (ការស្នាក់នៅរយៈពេលខ្លី) | ក្នុងរយៈពេលខ្លីត្រូវចូលនៅមណ្ឌលថែទាំ ហើយយើងខ្ញុំនឹងជួយការងារក្នុងជីវភាពប្រចាំថ្ងៃនិងហ្វឹកហាត់ប្រព័ន្ធសរីរាង្គកាយ។ |
| | ការថែទាំនៅមណ្ឌល (សេវាកម្មប្រចាំថ្ងៃ) | ទៅមជ្ឈមណ្ឌលសេវាកម្មប្រចាំថ្ងៃ ដើម្បីធ្វើការជួយទ្រទ្រង់ជីវភាពប្រចាំថ្ងៃដូចជាការបរិភោគនិងងូតទឹកជាដើម។ |
| សេវាកម្មទៅដល់គេហដ្ឋាន | ការថែទាំតាមគេហដ្ឋាន | ជំនួយការម្នាក់នឹងមកផ្ទះរបស់អ្នក ហើយជួយការងារអ្នកក្នុងជីវភាពប្រចាំថ្ងៃ។ |
| | ការមើលថែទាំតាមគេហដ្ឋាន | ក្រោមការណែនាំរបស់វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកានឹងមកផ្ទះរបស់អ្នកដើម្បីជួយត្រួតពិនិត្យសុខភាពនិងអាការៈ |
| | ការស្តារនីតិសម្បទានៅតាមផ្ទះ | ក្រោមការបញ្ជាពីវេជ្ជបណ្ឌិត ពេទ្យព្យាបាលរាងកាយនឹងមកដល់ផ្ទះ ហើយធ្វើការស្តារនីតិសម្បទាដើម្បីជួយថែរក្សានិងស្តារ ប្រព័ន្ធរាងកាយអោយល្អប្រសើរឡើងវិញនិងជួយអ្នកមានភាពឯករាជ្យនៅក្នុងជីវភាពប្រចាំថ្ងៃ។ |

## (២) មណ្ឌលថែទាំ ចម្បង

សេវាកម្មថែទាំក៏មានផ្តល់ការថែទាំនៅតាមមណ្ឌលផងដែរ។
នៅទីនេះយើងខ្ញុំនឹងណែនាំមណ្ឌលថែទាំសុខុមាលភាពមនុស្សចាស់និងមណ្ឌលថែទាំមនុស្សចាស់ដែលជាតំណាងមណ្ឌលថែទាំចម្បង។

### តើអ្វីទៅជាមណ្ឌលសុខភាពថែទាំមនុស្សចាស់(មណ្ឌលមនុស្សចាស់)

#### ■ ទិដ្ឋភាពទូទៅ

គឺជាមណ្ឌលដែលផ្តល់សេវាកម្មប្រចាំថ្ងៃដូចជាការថែទាំ ការស្តារនីតិសម្បទា អាហារ ងូតទឹកជាដើម សម្រាប់អ្នកដែលបានចេញពីមន្ទីរពេទ្យ ហើយនឹងត្រឡប់ទៅផ្ទះវិញ ត្រូវការព្យាបាលឬមើលថែទាំ ។

#### ■ មនុស្សគោលដៅ

គឺអ្នកដែលមិនចាំបាច់ត្រូវគេងព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែត្រូវការការមើលថែទាំដើម្បីស្តារនីតិសម្បទា
(អ្នកដែលបានទទួលការបញ្ជាក់ពីតម្រូវការថែទាំ ១ ឡើងទៅ។)

#### ■ ខ្លឹមសារសេវាកម្ម



・ការស្តារនីតិសម្បទាដោយពេទ្យព្យាបាលរាងកាយ ពេទ្យព្យាបាលចលនា។ ល។
・ការថែទាំ / ថែទាំវេជ្ជសាស្ត្រ (ការពិនិត្យ ពិសោធន៍ ថ្នាំ។ ល។ )
・ការថែទាំលើជីវភាពរស់នៅប្រចាំថ្ងៃ
(ម្ហូបអាហារ ងូតទឹក ការ សម្រួលការបន្ទោបង់ជាដើម)
・ផ្សេងៗ (ជួយពិគ្រោះយោបល់ ការកម្សាន្ត។ល។)

### តើមណ្ឌលសុខុមាលភាពថែទាំមនុស្សចាស់(មណ្ឌលថែទាំមនុស្សចាស់ពិសេស)ជាអ្វី?

#### ■ ទិដ្ឋភាពទូទៅ

គឺជាកន្លែងផ្តល់ការថែទាំលើជីវភាពទូទៅចំពោះមនុស្សចាស់ដែលមានការលំបាកលើជីវភាពរស់នៅផ្ទះ ហើយត្រូវការការថែទាំគ្រប់ពេលវេលា ។

#### ■ មនុស្សគោលដៅ

អ្នកដែលត្រូវការការថែទាំគ្រប់ពេល ហើយមានការលំបាកលើជីវភាពរស់នៅនៅផ្ទះ គឺជាមនុស្សគោលដៅ។
(អ្នកដែលត្រូវបានទទួលការបញ្ជាក់ពីការមើលថែទាំ ៣ ឡើងទៅ។ )
(ក្នុងករណីដែលបានគេទទួលស្គាល់ថាជីវភាពរស់នៅនៅផ្ទះពិបាក យោងទៅលើមូលហេតុដែលមិនអាចចៀសបានអំពីការមើលថែ ១ និង ២ គឺអាចចូលជាករណីពិសេសដោយមានការចូលរួមសមស្របពីក្រុងឃុំភូមិ) ។

#### ■ ខ្លឹមសារសេវាកម្ម



・ការថែទាំលើជីវភាពប្រចាំថ្ងៃ (ម្ហូបអាហារ ងូតទឹក ការសម្រួលការបន្ទោបង់)
・ការហ្វឹកហាត់ប្រព័ន្ធរាង្គកាយ (ស្តារនីតិសម្បទា។ល។)
・ការគ្រប់គ្រងសុខភាពប្រចាំថ្ងៃ (ការត្រួតពិនិត្យទូទៅ ។ល។)
・ផ្សេងៗ (ពិគ្រោះយោបល់ ការកម្សាន្ត។ល។)

## (៣) មុខងារផ្សេងៗដែលធ្វើការនៅតាមមណ្ឌលថែទាំ

មានការងារផ្សេងៗជាច្រើននៅមណ្ឌលថែទាំឬសេវាកម្មថែទាំ ហើយក៏មានប្រភេទការងារជាច្រើនផងដែររបស់អ្នកធ្វើការនៅមណ្ឌលថែទាំ។

ដំបូងខ្ញុំនឹងពន្យល់អំពីទិដ្ឋភាពទូទៅរបស់ការងារថែទាំ។

### តើការងារថែទាំជាអ្វី?

#### ■ ទិដ្ឋភាពទូទៅ

វាជាការងារអាជីពដែលផ្តល់សេវាកម្មចាំបាច់លើជីវភាពប្រចាំថ្ងៃដោយនៅជាប់ការរស់នៅរបស់មនុស្សចាស់។

#### ■ តើជាការងារប្រភេទបែបណា

វាគឺជាការងារជួយទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់មនុស្សចាស់

ក្នុងការជួយថែទាំដូចជាម្ហូបអាហារ ងូតទឹក ទៅបន្ទប់ទឹកជាដើម មិនត្រឹមតែត្រូវការចំណេះដឹងផ្នែកជំនាញ និងជំនាញឯកទេសតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវមានការច្នៃប្រឌិត និងកម្លាំងរបស់មនុស្សចំពោះការងារនេះផងដែរ។

#### ■ តើមានការងារប្រភេទណាខ្លះ

ប្រភេទការងារចម្បងគឺមានដូចខាងក្រោម :



តារាង : ប្រភេទការងារនីមួយៗដែលធ្វើនៅតាមមណ្ឌលថែទាំ

| ប្រភេទការងារ | ខ្លឹមសារការងារ |
|---|---|
| អ្នកថែទាំសុខុមាលភាព បុគ្គលិកថែទាំ | យើងជួយនិងថែរក្សាបរិស្ថាននៅជុំវិញខ្លួនរបស់អ្នកប្រើប្រាស់ ហើយជួយគាំទ្រឱ្យពួកគាត់អាចមានជីវភាពរស់នៅប្រចាំថ្ងៃដោយសុខស្រួល។ |
| វេជ្ជបណ្ឌិត | បន្ទាប់ពីអាចគ្រប់គ្រងបានពីស្ថានភាពរបស់អ្នកប្រើប្រាស់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល គឺមានតែវេជ្ជបណ្ឌិតប៉ុណ្ណោះដែលអាចផ្តល់ការណែនាំទៅដល់គិលានុបដ្ឋាយិកានិងអ្នកជំនាញស្តារនីតិសម្បទា។ |
| គិលានុបដ្ឋាយិកា គិលានុបដ្ឋាយិការង | សហការជាមួយវេជ្ជបណ្ឌិតគ្រប់គ្រងអ្នកប្រើប្រាស់តាមបែបវេជ្ជសាស្ត្រ ព្រមទាំងប្រើចំណេះដឹងផ្នែកវេជ្ជសាស្ត្រផ្តល់ការថែទាំដ៏សមរម្យ។ |
| អ្នកព្យាបាលរាងកាយ (PT) | ផ្តល់ជូនដូចជាការស្តារនីតិសម្បទាជំនាញ បង្កើតផែនការស្តារនីតិសម្បទា វាយតម្លៃចំពោះអ្នកប្រើប្រាស់ជាដើម។ យើងនឹងអនុវត្តគម្រោងដើម្បីលើកកម្ពស់និងថែរក្សាអោយប្រសើរឡើង ដោយអ្នកព្យាបាលរាងកាយ PT គឺធ្វើឱ្យប្រសើរឡើងនូវមុខងារលំហាត់ប្រាណ អ្នកជំនាញព្យាបាលចលនា OT គឺរក្សាសមត្ថភាពចលនានិងការបន្សាំខ្លួនទៅនឹងសង្គម ហើយសវនករភាសា ST គឺរក្សានិងកែលម្អមុខងារនិយាយនិងការលេបអាហារចូល។ |
| អ្នកព្យាបាលធ្វើចលនា (OT) | |
| សវនករភាសា (ST) | |
| អ្នកគ្រប់គ្រងអាហារូបត្ថម្ភ / អ្នកជំនាញអាហារូបត្ថម្ភ | ដើម្បីថែរក្សានិងលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់អ្នកប្រើប្រាស់ យើងនឹងកំណត់ទម្រង់របបអាហារទៅតាមស្ថានភាពជាក់ស្តែង។ |
| ឱសថការី | យើងផ្តល់ការណែនាំស្តីពីការគ្រប់គ្រងនិងផ្តល់ជូនថ្នាំ។ |
| អ្នកអនាម័យមាត់ធ្មេញ | យើងធ្វើការណែនាំអំពីការថែទាំសុខភាពក្នុងមាត់ទៅដល់បុគ្គលិកថែទាំ និងអ្នកថែរក្សាអនាម័យក្នុងមាត់។ |
| អ្នកឯកទេសគាំទ្រការថែទាំ (ប្រធានផ្នែកថែទាំ) | យើងទទួលប្រឹក្សាយោបល់ពីអ្នកដែលត្រូវការការថែទាំ អ្នកដែលត្រូវការជំនួយ ឬក្រុមគ្រួសារ ។ល។ ដើម្បីជួយគាំទ្រឱ្យពួកគាត់អាចទទួលបានសេវាកម្មថែទាំសមស្របតាមស្ថានភាពរបស់ពួកគាត់។ |
| អ្នកផ្តល់ប្រឹក្សាគាំទ្រ (មណ្ឌលសុខភាពថែទាំមនុស្សចាស់) អ្នកប្រឹក្សាជីវភាពរស់នៅ (មណ្ឌលសុខុមាលភាពថែទាំមនុស្សចាស់) | ទទួលបន្ទុកក្នុងការបង្កើតគម្រោងថែទាំ និងសម្របសម្រួល ទំនាក់ទំនងដូចជា បុគ្គលិក វេជ្ជបណ្ឌិត គ្រូពេទ្យព្យាបាលរាងកាយ និងមន្ត្រីក្នុងតំបន់របស់មណ្ឌលថែទាំនេះ។ |
| ផ្សេងៗ | បុគ្គលិកសុខុមាលភាពសង្គម បុគ្គលិកការិយាល័យ ចុងភៅ ។ ល។ |

ប្រភេទការងារនិងបុគ្គលិកដែលបានលើកនៅទីនេះគឺគ្រាន់តែជាឧទាហរណ៍មួយចំណែកប៉ុណ្ណោះ ។ បុគ្គលិកដែលមានចំណេះដឹង និងជំនាញឯកទេសផ្សេងៗគ្នា គឺចូលរួមជួយគាំទ្រជីវភាពរស់នៅរបស់អ្នកប្រើប្រាស់ ហើយទាក់ទងការងារថែទាំជាក្រុម។

# ២. អំពីការងាររបស់ជំនួយការអ្នកថែទាំ

## ទិដ្ឋភាពទូទៅនៃជំនួយការអ្នកថែទាំ

ដូច្នេះតើ "ជំនួយការអ្នកថែទាំ" មានតួនាទីអ្វីខ្លះនៅក្នុងការងារថែទាំ? ហើយតើមានគុណសម្បត្តិនិងលក្ខណៈពិសេសអ្វីខ្លះ?




គឺជាការងារជួយទ្រទ្រង់បុគ្គលិកថែទាំនៅតាមមណ្ឌលថែទាំ និងមណ្ឌលថែទាំសុខភាព។
ការងារថែទាំគឺគ្របដណ្តប់លើមុខងារជាច្រើន ដូចជាជួយពេលញ៉ាំអាហារនិងជួយទ្រទ្រង់ភាពម្ចាស់ការ ប៉ុន្តែយើងមិនបានផ្តល់ការថែទាំដោយផ្ទាល់ដូចជា" ការជួយពេលទៅបង្គន់" ឬ" ការជួយងូតទឹក" ដល់អ្នកប្រើប្រាស់ទេ ក្រៅពីនេះគឺអនុវត្តចម្បងលើការងារជុំវិញការថែទាំ ។






គឺអាចវាស់ស្ទង់ការងារជំនាញឯកទេសលើការងារ
ថែទាំ និងការកើនឡើងនៃជំនួយការថែទាំ។




វាជាកន្លែងការងារសម្រាប់អ្នកដែលមាន
កម្លាំងចិត្តតែមិនមានឱកាសធ្វើការ។

# ៣. អំពីទិដ្ឋភាពទូទៅនៃការងារ

## ភាពខុសគ្នារវាងការងាររបស់បុគ្គលិកថែទាំនិងការងាររបស់ជំនួយការថែទាំ

រហូតមកដល់ពេលនេះខ្ញុំបានពន្យល់ខ្លីៗពីការងារថែទាំនិងការងាររបស់ជំនួយការថែទាំរួចហើយ។
ដូច្នេះតើអ្វីជាភាពខុសគ្នារវាងបុគ្គលិកថែទាំនិងជំនួយការថែទាំ?
ភាពខុសគ្នាធំបំផុតរវាងបុគ្គលិកថែទាំនិងជំនួយការថែទាំគឺនៅត្រង់ថាតើត្រូវមើលថែពួកគាត់ដោយផ្ទាល់ឬមិនផ្ទាល់។
ការងារថែទាំ (ការថែទាំរាងកាយដោយផ្ទាល់) គឺជាការងាររបស់បុគ្គលិកថែទាំ ហើយជំនួយការថែទាំត្រូវបានស្នើឱ្យធ្វើការងារអមជាមួយការថែទាំរាងកាយនិងការងារជុំវិញ។ សូមជំនួយការថែទាំគិតថាវាជាការងារ (ជួយបុគ្គលិកធ្វើការងារថែទាំ)។
សូមលើកយកកន្លែងអាហារធ្វើជាឧទាហរណ៍។
សូមស្រមៃមើលរូបភាពពេលបុគ្គលិកមើលថែទាំប្រើស្លាបព្រាបញ្ចុកបាយចូលទៅក្នុងមាត់អ្នកប្រើប្រាស់ដែលពិបាកលេបចូលដោយផ្ទាល់។ ក្នុងស្ថានភាពមួយទល់មួយបែបនេះ គឺបុគ្គលិកថែទាំមិនអាចមើលការពារស្ថានភាពរបស់អ្នកប្រើប្រាស់ដទៃទៀតដោយយកចិត្តទុកដាក់បានឡើយ។
ក្នុងស្ថានភាពបែបនឹង ជំនួយការថែទាំអាចយកចិត្តទុកដាក់លើស្ថានភាពរបស់អ្នកប្រើប្រាស់ផ្សេងទៀត ឬជួយលើកទឹកតែជូនជាដើម ដែលជាដំណើរការងារល្អិតល្អន់ក្នុងការផ្តល់សេវាកម្មថែទាំយ៉ាងពេញលេញបាន។

តារាង : ភាពខុសគ្នានៃការងាររវាងបុគ្គលិកថែទាំនិងជំនួយការថែទាំ (ឧទាហរណ៍១នៅកន្លែងអាហារ)

| 【បុគ្គលិកថែទាំ】<br>(ការថែទាំដោយផ្ទាល់) | 【ជំនួយការថែទាំ】<br>(ការងារជុំវិញ) |
|---|---|
| ជួយពេលទទួលទានអាហារ<br>មើលថែទាំអាហារ<br>បញ្ជាក់ពីបរិមាណទទួលទាន<br>ជួយពេលលេបថ្នាំ<br>រៀបចំទុកដាក់ចានអាហារ<br>ណែនាំអ្នកប្រើប្រាស់<br>ថែរក្សាអនាម័យក្នុងមាត់ | ចែកអៀមនិងកន្សែងសើម<br>ឆុងតែនិងលើកទឹកតែ<br>ការបម្រើ<br>ចែកឧបករណ៍ជួយស្វ័យប្រវត្តិ<br>មើលថែរក្សាអាហារ<br>សម្អាតរៀបចំអាហារដ្ឋាន<br>និយាយប្រាប់ពីបម្លាស់ទីដណ្តើរយន្ត |



## អំពីការងារជុំវិញចម្បង

ក្រៅពីកន្លែងទទួលទានអាហារ មានកិច្ចការជាច្រើនដែលទាក់ទងនឹងការមើលថែទាំនិងការងារជុំវិញនៅក្នុងមណ្ឌលថែទាំ ជាពិសេសមុខងារដូចខាងក្រោមត្រូវបានលើកឡើង។

### ■ ការគ្រប់គ្រង ថែទាំ និងសម្អាតមណ្ឌល



- សម្អាតបន្ទប់និងរៀបចំអាហារ
- រៀបចំគ្រែ ផ្លាស់ប្តូរស្រោមពូកខ្នើយ
- កែលម្អបរិស្ថានដូចជាខ្យល់ចេញចូល និងសំណើម
- បំពេញបន្ថែមឬផ្លាស់ប្តូរគ្រឿងបន្លាស់

### ■ ការជួយសម្រាប់ការរៀបចំនីមួយៗ

- បម្រើអាហារ
- រៀបចំនិងត្រៀមឧបករណ៍ជួយស្វ័យប្រត្តិនិងឧបករណ៍ស្តារនីតិសម្បទា
- ហៅប្រាប់នៅពេលផ្លាស់ប្តូរទីតាំង



### ■ ផ្សេងទៀត

- ឃ្លាំមើលថៃ
- ដៃគូនិយាយជាមួយ
- ជូនទៅមកពីមណ្ឌលថែទាំនិងផ្ទះ
- ជួយដល់សកម្មភាពដែលជាចំណង់ចំណូលចិត្តដូចជាការថៃសួន

។ល។






# ៤. អំពីខ្លឹមសារការងារអនុវត្តជាក់ស្តែង

## (១) ភារកិច្ចជាក់លាក់របស់ជំនួយការថែទាំ

មកដល់ទំព័រមុន យើងបានណែនាំអំពីការងារ (ការងារជុំវិញ) ដែលអនុវត្តដោយជំនួយការថែទាំ។ ចាប់ពីពេលនេះតទៅ នៅពេលដែលអ្នកសម្រេចចិត្តធ្វើការនៅមណ្ឌលថែទាំក្នុងនាមជាជំនួយការថែទាំ យើងនឹងទៅមើលយ៉ាងស៊ីជម្រៅទៅលើ" ភារកិច្ចដែលអ្នកនឹងត្រូវបានស្នើសុំអោយអនុវត្ត"។

ការងារជំនួយការថែទាំត្រូវបានចាត់ថ្នាក់ការលំបាក ហើយបែងចែកការលំបាកត្រូវបានគេហៅថា "ថ្នាក់" នៅក្នុងការណែនាំនេះ។ "ថ្នាក់" ត្រូវបានបែងចែកជាបីដំណាក់កាលគឺពី C ដល់ A ពី ភារកិច្ចដែលអាចអនុវត្តបានដោយមិនចាំបាច់មានចំណេះដឹងថែទាំ ដល់ភារកិច្ចដែលត្រូវការកម្រិតជំនាញជាក់លាក់មួយ។

### អំពីថ្នាក់ការងារជុំវិញដែលអនុវត្តដោយជំនួយការថែទាំ

#### ■ ថ្នាក់C

គឺជាការងារដែលត្រូវបានគេចងក្រងជាសៀវភៅណែនាំនិងមានលំនាំគម្រូដែលមានភាពងាយស្រួលចំពោះអ្នកដែលសឹងតែគ្មានចំណេះដឹងនិងជំនាញឯកទេសក៏អាចធ្វើការបានដែរ ជាទូទៅមានការងារដូចជាការសម្អាត ការរៀបចំមណ្ឌលថែទាំអោយមានសណ្តាប់ធ្នាប់ល្អ ការរៀបចំត្រៀមឧបករណ៍គ្រឿងបន្លាស់ផ្សេងៗជាដើម។

#### ■ ថ្នាក់B

គឺជាការងារមួយដែលទាមទារចំណេះដឹងនិងជំនាញឯកទេសដែលអាចទទួលបានតាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី ជាពិសេសវារួមបញ្ចូលការងាររៀបចំគ្រែគេងតាមសកម្មភាពជីវភាពប្រចាំថ្ងៃ និងការប្រុងប្រយ័ត្ននៅពេលបម្រើការងារទៅតាមស្ថានភាពរបស់អ្នកប្រើប្រាស់ជាដើម។

#### ■ ថ្នាក់A

គឺជាការងារដែលមានការប្រៀបធៀបកម្រិតដែលទាមទារត្រូវមានចំណេះដឹង ជំនាញ និងបទពិសោធន៍ជាក់លាក់ក្នុងកម្រិតណាមួយ។
(ដូចជា មើលថែទាំគាត់ និយាយជាមួយគាត់ ជួយគាត់ក្នុងសកម្មភាពចំណូលចិត្តរបស់គាត់ជាដើម)

អំពីថ្នាក់និងខ្លឹមសារការងារ អាចនឹងមានការខុសគ្នានៅតាមមណ្ឌលថែទាំដែលអ្នកធ្វើការជាក់ស្តែងនិងពីអ្វីដែលបានណែនាំនៅក្នុងសេចក្តីណែនាំ។
នេះដោយសារតែខ្លឹមសារនៃការងារជុំវិញ វាមានភាពខុសគ្នាអាស្រ័យលើមណ្ឌលថែទាំ។ ហើយម្យ៉ាងទៀត ទោះបីជាខ្លឹមសារការងារដូចគ្នាក៏ដោយ តែអាចផ្លាស់ប្តូរការអនុវត្តសម្របសម្រួលផងដែរ អាស្រ័យលើអ្នកប្រើប្រាស់ ដូច្នេះការចាត់ថ្នាក់សូមយកទុកជាជំនួយបន្ថែមតែប៉ុណ្ណោះ។
ព័ត៌មានលម្អិតនៃការងារ សូមបញ្ជាក់បន្ថែម ព្រោះអ្នកអាចដឹងការណែនាំឬការបណ្តុះបណ្តាលពីអ្នកទទួលខុសត្រូវដែលធ្វើការនៅមណ្ឌលថែទាំនោះ។
ដូច្នោះ សូមទៅមើលខ្លឹមសារភារកិច្ចការងារនៃថ្នាក់នីមួយៗ។

## អំពីភារកិច្ចការងារជុំវិញតាមថ្នាក់នីមួយៗ

### ថ្នាក់C

"ថ្នាក់C"គឺជាការងារដែលត្រូវបានគេចងក្រងជាសៀវភៅណែនាំឬលំនាំគម្រូដែលមានលក្ខណងាយស្រួល អាចអនុវត្តបានសូម្បីតែអ្នកដែលមានចំណេះដឹងឬជំនាញឯកទេសតិចតួចក៏ដោយ។ អ្នកដែល ពាក់ព័ន្ធនឹងការងារថែទាំជាលើកដំបូង ឬ អ្នកដែលចង់ចាប់ផ្តើមពីការដឹងការងារមូលដ្ឋានគ្រឹះរបស់មជ្ឈមណ្ឌលថែទាំ គឺចាប់ផ្តើមពីថ្នាក់នេះទៅ។

តារាង : ខ្លឹមសារការងារថ្នាក់C

| ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ខ្លឹមសារការងារ (តូច) |
|---|---|---|
| ភ្ញាក់ពីគេង | ការរៀបចំពេលភ្ញាក់ឡើង | រៀបចំលម្អបរិស្ថានដូចជាការបើកវាំងនននិងប្រព័ន្ធខ្យល់ចេញចូល |
| អាហារ | ការរៀបចំនិងរៀបទុកដាក់អាហារ | សម្អាតតុ |
| | | ចែកអៀមនិងកន្សែងសើម |
| | | លាងសម្អាតចាននិងជូតសម្អាតឧបករណ៍ជួយស្វ័យប្រវត្ត |
| | | សម្អាតបន្ទប់អាហារ(សម្អាតតុនិងជាន់ផ្ទាល់ដី) |
| ការបោស សម្អាត | ការសម្អាតបន្ទប់ទទួលភ្ញៀវនិងតំបន់រួម | ការថែរក្សាឧបករណ៍បម្លែងសំណើមនិងខ្យល់ចេញចូលនៅក្នុងមណ្ឌល |
| | | ការលាងសម្អាតជាន់ផ្ទាល់ដី និងជូតបង្កាន់ដៃ |
| | | សម្អាតបង្គន់ |
| | | ផ្លាស់ប្តូរកម្រាលពូក |
| | | រៀបចំសម្អាតតុបតែងគ្រែគេង |
| | | បោះសម្រាមចោល |
| | | បំពេញបន្ថែមវត្ថុប្រើប្រាស់ |
| បោកគក់ | បោកគក់និងរៀបចំទុកដាក់ការបោកគក់ | បោកគក់ |
| | | បត់របស់បោកគក់និងសងត្រលប់ទៅវិញ |
| | | ធ្វើកន្សែងសើម |
| ចូលអាងងូតទឹក | ត្រៀមនិងរៀបចំអាងងូតទឹក | លាយទឹកក្តៅ |
| | | ត្រៀមសម្លៀកបំពាក់ចូលអាងងូតទឹក |
| | | លាងសម្អាតបន្ទប់ទឹក |
| | | បំពេញបន្ថែមរបស់របរប្រើប្រាស់ |
| គ្រប់គ្រងថែទាំ | គ្រប់គ្រងថែទាំមណ្ឌល | លាងសម្អាតរថយន្ត |
| | | មើលថែទាំរុក្ខជាតិ (ស្រោចទឹក) |
| | | ផ្លាស់ប្តូរ បំពេញបន្ថែម ពិនិត្យរបស់របរប្រើប្រាស់ |
| ការព្យាបាលនីតិសម្បទា | ការព្យាបាលនីតិសម្បទា | រៀបចំទុកដាក់របស់របរប្រើប្រាស់ |
| ការ កម្សាន្ត | ការរៀបទុកដាក់និងរៀបចំការកម្សាន្ត | ការរៀបចំត្រៀមឧបករណ៍និងវត្ថុរបស់គម្រោង |
| | | រៀបចំទុកដាក់ឧបករណ៍នានា |
| ចូលគេង | ការៀបចូលគេង | រៀបចំត្រៀមសម្លៀកបំពាក់ផ្លាស់ប្តូរថ្ងៃបន្ទាប់ |

## ថ្នាក់B

"ថ្នាក់B" គឺជាការងារដែលទាមទារត្រូវមានចំណេះដឹងនិងជំនាញឯកទេសដែលអាចទទួលបានតាមរយៈការបណ្តុះបណ្តាលរយៈពេលខ្លី។ អ្នកអាចបោះជំហានទៅមុខបាន១ជំហានទៀត បន្ទាប់ពីទទួលបានបទពិសោធន៍ក្នុងការងារឬបានទទួលការបណ្តុះបណ្តាលថ្នាក់ C រួចហើយ។ លើសពីនេះទៀត អ្នកដែលមានបទពិសោធន៍ក្នុងការថែទាំឬវេជ្ជសាស្ត្រ (មានប្រវត្តិការងារ ឬមានសញ្ញាបត្រ ។ ល។) នឹងត្រូវចូលរួមក្នុងការងារថ្នាក់ B ស្របនឹងការងារថ្នាក់ C ។

តារាង : ខ្លឹមសារការងារថ្នាក់B

| ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ខ្លឹមសារការងារ (តូច) |
|---|---|---|
| ភ្ញាក់ពីគេង | ការរៀបភ្ញាក់ពីគេង | រៀបចំបំពេញបន្ថែមសារធាតុទឹក |
| អាហារ | រៀបចំត្រៀមអាហារនិងរៀបចំទុកដាក់ | ចែកចាយឧបករណ៍ជួយស្វ័យប្រវត្ត។ ល។ |
| | | ការបម្រើលើកទឹកតែ |
| | | សារចានអាហារ |
| បោសសម្អាត | សម្អាតបន្ទប់ទទួលភ្ញៀវ និងតំបន់រួម | រៀបចំគ្រែគេង |
| ចូលអាងងូតទឹក | ជួយពេលចូលងូតទឹក | រៀបចំបន្ថែមសារធាតុទឹក |
| ការកម្សាន្ត | ការរៀបចំការកម្សាន្ត/ដំណើរការ | គម្រោង/ការរៀបចំ |
| | | ដំណើរការ/សាស្ត្រាចារ្យ |



## ថ្នាក់A

"ថ្នាក់ A" គឺជាការងារមានការប្រៀបធៀបកម្រិតខ្ពស់ដែលទាមទារកម្រិតចំណេះដឹង ជំនាញនិងបទពិសោធន៍ជាក់លាក់មួយ។ អ្នកអាចបោះជំហានទៅមុខបានបន្ទាប់ពីទទួលបានបទពិសោធន៍ការងារឬទទួលបានការបណ្តុះបណ្តាលថ្នាក់ B ។

តារាង : ខ្លឹមសារការងារថ្នាក់ A

| ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ខ្លឹមសារការងារ (តូច) |
|---|---|---|
| អាហារ | ការជួយ /រៀបចំអាហារ | លាយគ្រឿងរុម៉ី |
| | | ការហៅបម្លាស់ប្តូរទៅអាហារដ្ឋាន |
| | | មើលថែរក្សា |
| បន្ទប់ទឹក | ជំនួយពេលចូលបន្ទប់ទឹក | ហៅប្រាប់ធ្វើបម្លាស់ទីទៅបន្ទប់ទឹក (ហៅប្រាប់អ្នកដែលស្លៀកខោខ្លីក្រណាត់) |
| ចូលងូតទឹកអាង | ជំនួយនៅពេលងូតទឹក | ហៅប្រាប់ធ្វើបម្លាស់ទីទៅបន្ទប់ងូតទឹក |
| | | មើលថែទាំ |
| | | ផ្លុំសក់ |
| ការព្យាបាលនីតិសម្បទា | ការជួយព្យាបាលនីតិសម្បទា | ការជួយព្យាបាលដោយធ្វើចលនា (កញ្ចប់ក្តៅ។ ល។ ) |
| | | មើលការពារការហ្វឹកហាត់ខ្លួនឯង |
| ការកម្សាន្ត | ជួយធ្វើការងារ និងដំណើរការនៃការកម្សាន្ត | ជួយសកម្មភាពចំណង់ចំណូលចិត្ត |
| | | គម្រោង |
| | | ប្រាប់នៅពេលផ្លាស់ទីតាំង |
| | | ដំណើរការ / គ្រូ / ការគាំទ្រ |
| ផ្សេងៗ | បម្លាស់ទី | មើលថែទាំនិងហៅប្រាប់ពេលផ្លាស់ទីរទេះរុញ |
| | | មើលថែទាំនិងហៅប្រាប់នៅពេលត្រូវដើរ |
| | ផ្សេងៗ | មើលថែទាំនៅក្នុងមណ្ឌល |
| | | ការសន្ទនា |
| | | ជូនទៅមកដោយរថយន្ត |



## (២) ឧទាហរណ៍លម្អិតក្នុង១ថ្ងៃរបស់ជំនួយការថែទាំ

បន្ទាប់មក សូមសាកល្បងអនុវត្តទៅនឹងលំហូរការងារក្នុង១ថ្ងៃនៃការងារជុំវិញរបស់ថ្នាក់ C ដល់ A ដែលបានបង្ហាញនៅក្នុងផ្នែកមុននេះ។

ឧទាហរណ៍ ប្រសិនបើអ្នកទទួលបន្ទុកថ្នាក់ C គឺខ្លឹមសារនៃ "ខ្លឹមសារការងារ (តូច)" នៅក្នុងជួរ C នៃ "ការងាររបស់ជំនួយការអ្នកថែទាំ (តាមថ្នាក់)" នឹងក្លាយជាការងារដែលអ្នកត្រូវទទួលបន្ទុកអនុវត្ត។

តារាង : លំហូរក្នុង១ថ្ងៃ (ឧទាហរណ៍)

| ម៉ោង | ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ខ្លឹមសារការងារ (តូច) | ការងាររបស់បុគ្គលិកថែទាំ | ការងាររបស់ជំនួយការថែទាំ (តាមថ្នាក់) |
|---|---|---|---|---|---|
| ពេលព្រឹក | ក្រោកពីគេង | រៀបចំពេលក្រោកពីគេង | បើកវាំងនន | | C |
| | | | រៀបចំបំពេញបន្ថែមសារធាតុទឹក | | B |
| | | បង្គន់ | ហៅប្រាប់ពេលបម្លាស់ទីទៅបង្គន់ | | A |
| | | | ជួយពេលទៅបង្គន់ | ● | |
| | | ស្លៀកពាក់ខោអាវ | ស្លៀកពាក់/តុបតែង/ពាក់ធ្មេញអោយសមរម្យ | ● | |
| | អាហារ | អាហារពេលព្រឹក | សម្អាតតុ | | C |
| | | | ចែកអៀមនិងកន្សែងសើម | | C |
| | | | ហៅបម្លាស់ទីទៅអាហារដ្ឋាន | | A |
| | | | ការបម្រើ/ លើកទឹកតែ | | B |
| | | | ជួយពេលទទួលទានអាហារ / បញ្ជាក់បរិមាណអាហារ | ● | |
| | | | មើលថែទាំ | | A |
| | | | រៀបចំចានទុកដាក់ | | B |
| | | | លាងចានបម្លាស់ផ្ទះបាយ | | C |
| | | | ការថែរក្សាសុខភាពមាត់ | ● | |
| ថ្ងៃត្រង់ | សម្អាត | សម្អាតបរិវេណរួមនិងបន្ទប់នៅ | សម្អាត/ផ្លាស់ប្តូរខ្យល់ | | C |
| | | | លាងបង្គន់ | | C |
| | | | បំពេញបន្ថែមរបស់របរប្រើប្រាស់ / បោះចោលសម្រាម | | C |
| | | សម្អាតបន្ទប់នៅ | ប្តូរស្រោមពូក | | C |
| | | | រៀបចំគ្រែគេង | | B / C |
| | | បោកគក់ | បោកគក់ | | C |
| | ការព្យាបាលនីតិសម្បទា | ការព្យាបាលនីតិសម្បទា | ការអនុវត្តនិងហ្វឹកហាត់ | ● | |
| | | | ការជួយការព្យាបាលដោយចលនា | | A |
| | | | ឃ្លាំមើលការអនុវត្តខ្លួនឯង | | A |
| | | | រៀបចំទុកដាក់របស់របរប្រើប្រាស់ | | C |

### ★ចំណុចរបស់ជំនួយការថែទាំ៖ តោះចាប់ផ្តើមជាមួយ" អ្វីដែលអ្នកអាចធ្វើបាន"

អំពីខ្លឹមសារការងារឬថ្នាក់គឺអាចខុសគ្នាពីអ្វីដែលបានណែនាំនៅក្នុងការណែនាំនេះ អាស្រ័យលើមណ្ឌលដែលអ្នកធ្វើការជាក់ស្តែង។ នេះដោយសារតែខ្លឹមសារការងារជុំវិញ គឺខុសគ្នាទៅតាមមណ្ឌល។ ម្យ៉ាងទៀត ទោះបីជាខ្លឹមសារការងារគឺដូចគ្នាក៏ដោយ ប៉ុន្តែការឆ្លើយតបទៅអ្នកប្រើប្រាស់គឺអាចប្រែប្រួល ដូច្នេះខ្លឹមសារនៃការចាត់ថ្នាក់គឺសូមទុកជាខ្លឹមសារយោងតែប៉ុណ្ណោះ។

ក្នុងចំនុចប្រុងប្រយ័ត្ន ទោះបីជា"ថ្នាក់ A " ក៏ដោយ សកម្មភាពលើការថែទាំដោយផ្ទាល់ ដូចជាការអោយខ្ចីដៃនៅពេលក្រោកពីរទេះរុញ គឺលើកលែងបានតែករណីមណ្ឌលបានយល់ព្រមនៅពេលមានអាសន្នឬនៅពេលមិនអាចជៀសផុតតែប៉ុណ្ណោះ ជាមូលដ្ឋានសូមបញ្ឈប់ត្រឹមតែការហៅប្រាប់ឬមើលថែទាំបានហើយ។

ប៉ុន្តែអ្នកមិនចាំបាច់ធ្វើអោយហួសច្រើនជាងអ្វីដែលចាំបាច់នោះទេ។

ប្រសិនបើអ្នកមានបញ្ហាដូចជា តើខ្ញុំអាចធ្វើការងារបន្តទៅមុខបានត្រឹមណា។ល។ សូមសុំការណែនាំនៅក្នុងការសន្ទនាជាមួយបុគ្គលិកថែទាំ។

ម្យ៉ាងវិញទៀត បុគ្គលិកថែទាំផងដែរ មានរឿងជាច្រើនត្រូវជួយនិងប្រាប់មកពីអ្នកទាំងអស់គ្នាមកវិញក៏មានដែរ។

ឧទាហរណ៍ ក្នុងនាមមើលថែទាំ គ្រាន់តែកើនឡើងនូវបុគ្គលិកដែលយកចិត្តទុកដាក់ទៅអ្នកប្រើប្រាស់គឺពិតជួយបានច្រើនណាស់ទៅហើយ។ នេះក៏ព្រោះតែអ្នកអាចបំពេញភារកិច្ចផ្សេងៗបាន ហើយវាជួយបង្កើនសុវត្ថិភាពផ្លូវចិត្តបាន។

ហើយម្យ៉ាងទៀត ក្នុងការជួយរៀបចំផែនការនិងគាំទ្រចំណង់ចំណូលចិត្តកម្សាន្តប្រសិនបើអ្នកអាចប្រាប់យើងពីអ្វីដែលអ្នកពូកែនិងចំណង់ចំណូលចិត្តរបស់អ្នក វានឹងធ្វើឱ្យមានភាពសកម្មនៅក្នុងមណ្ឌល។

សូមផ្លាស់ប្តូរការផ្លាស់ប្តូរទំនាក់ទំនងជាមួយសហគមន៍តាមរយៈការងារជាជំនួយការអ្នកថែទាំនេះ។



# ឯកសារណែនាំប្រាប់នៅពេលទទួលយកជំនួយការថែទាំ

## អំពីចំណុចប្រុងប្រយ័ត្នកំឡុងពេលការងារ

ចំពោះអ្វីៗដែលទាក់ទងនឹងការងារថែទាំ មានចំណុចត្រូវប្រុងប្រយ័ត្នដាច់ខាតមួយចំនួនដើម្បីគាំទ្រដល់ជីវភាពរបស់អ្នកប្រើប្រាស់ចង់បាន។ នៅទីនេះ យើងនឹងពន្យល់ចំណុចទាំងនោះ។

### ចំណុចប្រុងប្រយ័ត្ន(១): អ្វីដែលអ្នកមិនអាចធ្វើ

នៅពេលផ្លាស់ទីទៅញ៉ាំអាហារឬទៅបង្គន់សូមនិយាយប្រាប់ពួកគាត់។
ឧទាហរណ៍ ពេលញ៉ាំបាយបើទោះបីជាបុគ្គលិកថែទាំនៅនឹងកន្លែងរវល់ក៏ដោយ ជំនួយការថែទាំមិនអាចជួយបញ្ចុកអាហារដោយចិត្តខ្លួនឯងទេ។ ដោយមានវត្តមានអ្នកដែលពិបាកលេបអាហារចូលឬហានិភ័យនៃការញ៉ាំចូលដោយចៃដន្យ ការជួយពេលទទួលអាហារតម្រូវឱ្យមានការប្រុងប្រយ័ត្នខ្ពស់ផ្អែកលើបទពិសោធន៍។ ក្រៅពីការជួយពេលទទួលទានអាហារ អំពីការងារដែលត្រូវជួយដូចជាពេលចូលបង្គន់ឬងូតទឹកក៏ត្រូវប្រុងប្រយ័ត្នដូចគ្នាដែរ។
ម្យ៉ាងទៀត គឺត្រូវលាងដៃ ខ្ពុលមាត់ និងពាក់ម៉ាស់ជាដាច់ខាត ដើម្បីការពារជំងឺឆ្លង។

### ចំណុចប្រុងប្រយ័ត្ន(២):ការប្រកាន់ភ្ជាប់យ៉ាងតឹងរឹងចំពោះការរក្សាការពារព័ត៌មានផ្ទាល់ខ្លួន (ឯកជន)

ត្រូវតែយល់ថាអ្នកប្រើប្រាស់គឺជាមនុស្សម្នាក់ដែលមានបុគ្គលិកលក្ខណៈនិងឆន្ទៈ ហើយត្រូវតែថែរក្សាការពារ។
ការថែទាំគឺជាការងារសំខាន់មួយ ដែលមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងភាពឯកជនផ្ទាល់ខ្លួន
ដូច្នេះយើងត្រូវគោរពបុគ្គលិកលក្ខណៈរបស់អ្នកប្រើប្រាស់ ព្រមទាំងយកចិត្តទុកដាក់ប្រុងប្រយ័ត្នអោយបានខ្ជាប់ខ្ជួនលើការរក្សាការពារភាពឯកជនរបស់បុគ្គលនោះ។
ការមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកប្រើប្រាស់ គឺមានន័យថាទាក់ទងជាមួយព័ត៌មានផ្ទាល់ខ្លួនច្រើនដែរ។
ព័ត៌មានដែលទទួលបាននៅទីនេះគឺមិនអាចប្រាប់ទៅអ្នកខាងក្រៅបានជាដាច់ខាត។
ថ្មីៗនេះ ការផ្ញើសារ និងគេហទំព័រផុសផ្សាយវីដេអូ គឺអាចប្រើបានហើយ ប៉ុន្តែសេវាកម្មទាំងនេះមានភាពងាយស្រួលក៏ដោយ ផ្ទុយពីនេះវិញព័ត៌មានដែលត្រូវបានចុះផ្សព្វផ្សាយម្តង គឺត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងរយៈពេលដ៏ខ្លី ហើយវាពិបាកក្នុងការលុបវាចោលវិញខ្លាំងណាស់។ ដូចនេះសូមកុំប្រើវានៅកន្លែងធ្វើការ។

**★ចំណុចរបស់ជំនួយការថែទាំៈច្បាប់ស្តីពីការរក្សាការសម្ងាត់ដែលបុគ្គលិកថែទាំត្រូវគោរពអោយបាន**

**[ឯកសារយោង] ស្តង់ដារអំពីប្រតិបត្តិការនិងគ្រឿងបរិក្ខារនិងមណ្ឌល, បុគ្គលិករបស់មណ្ឌលថែទាំសុខភាពមនុស្សចាស់ (បទបញ្ជាក្រសួងសុខាភិបាលលេខ ៤០)**

(ការរក្សាការសម្ងាត់។ ល។)
មាត្រា ៣២.- និយោជិកនៃមណ្ឌលថែទាំសុខភាពមនុស្សចាស់ ហាមមិនអោយធ្លាយរឿងអាថ៌កំបាំងរបស់អ្នកចូលនៅមណ្ឌលឬគ្រួសាររបស់ពួកគាត់ដែលបានស្គាល់នៅពេលធ្វើការងារដោយគ្មានហេតុផលត្រឹមត្រូវឡើយ។
(២) មណ្ឌលសុខភាពថែទាំមនុស្សចាស់ ត្រូវចាត់វិធានការចាំបាច់ដើម្បីកុំអោយអ្នកដែលជានិយោជិកធ្វើអោយបែកធ្លាយអាថ៌កំបាំងរបស់អ្នកចូលនៅមណ្ឌលឬគ្រួសាររបស់ពួកគេ ដែលខ្លួនបានដឹងកំឡុងពេលធ្វើការងារ ដោយគ្មានហេតុផលត្រឹមត្រូវណាមួយឡើយ។
(៣) មណ្ឌលសុខភាពថែទាំមនុស្សចាស់ នៅពេលផ្តល់ព័ត៌មានអំពីអ្នកចូលនៅមណ្ឌលដល់ក្រុមហ៊ុនគាំទ្រការថែទាំនៅតាមផ្ទះ។ល។ គឺត្រូវតែទទួលការយល់ព្រមពីអ្នកចូលនៅក្នុងមណ្ឌលជាលាយលក្ខណ៍អក្សរជាមុនសិន។

## ចំណុចប្រុងប្រយ័ត្ន(៣): ជៀសវាងហ៊ីយ៉ារីហាតុ

ខ្ញុំសូមណែនាំឧទាហរណ៍នៃហ៊ីយ៉ារីហាតុដែលជាចំណុចប្រុងប្រយ័ត្នមួយទៀត ។
ហ៊ីយ៉ារីហាតុគឺជាព្រឹត្តិការណ៍មួយដែលអ្នកធ្វើការអាចធ្វើឱ្យមានការធ្វើប្រហែស"បីសនឹង" ឬ "រៀបនឹងកើតឡើង" នៅក្នុងសេវាកម្មប្រចាំថ្ងៃ ទោះបីជាវាមិនបង្កការខូចខាតដល់អ្នកប្រើប្រាស់ក៏ដោយ។

### ឧទាហរណ៍១របស់ហ៊ីយ៉ារីហាតុ : គ្រោះថ្នាក់ដោយសារតែការភ្លេចទុកដាក់ឧបករណ៍ឱ្យបានត្រឹមត្រូវ

[ព្រឹត្តិការណ៍] អ្នកប្រើប្រាស់ហៀបនឹងប៉ះទង្គិចនឹងឧបករណ៍សម្អាតដែលមានទុកនៅក្នុងច្រករបងទ្វារផ្ទះ

[មូលហេតុ] មិនបានគ្រប់គ្រងឧបករណ៍ឱ្យបានត្រឹមត្រូវ។
លើសពីនេះទៀត ការបញ្ជាក់មិនគ្រប់គ្រាន់នៃវត្ថុគ្រោះថ្នាក់នៅលើខ្សែចលនារបស់អ្នកប្រើប្រាស់។

### ឧទាហរណ៍២របស់ហ៊ីយ៉ារីហាតុ : គ្រោះថ្នាក់ក្នុងពេលកម្សាន្ត

[ព្រឹត្តិការណ៍] នៅពេលអ្នកប្រើប្រាស់កំពុងសប្បាយរីករាយនឹងខារ៉ាអូខេ អ្នកប្រើប្រាស់ម្នាក់ទៀត
បានទាក់ជើងនឹងខ្សែមីក្រូហើយរៀបនឹងជំពប់ជើងដួលទៅហើយ។

[មូលហេតុ] ខ្ញុំមិនដឹងពីទីតាំងនៃប្រពន្ធ័ខ្សែរបស់មីក្រូហ្វូន ឬឧបករណ៍ទេ។
លើសពីនេះទៀត ការមើលថែការពារសកម្មភាពរបស់អ្នកប្រើប្រាស់គឺមិនគ្រប់ជ្រុងជ្រោយទេ។

### ឧទាហរណ៍៣របស់ហ៊ីយ៉ារីហាតុ : ការលេបចូលពេលបរិភោគអាហារ

[ព្រឹត្តិការណ៍] នៅពេលបុគ្គលិកមិនបានមើលអ្នកប្រើប្រាស់បានលេបក្រូចទាំងមូលចូល។

[មូលហេតុ] កង្វះការយកចិត្តទុកដាក់ ឬកង្វះការសង្កេតមើលថែទាំអ្នកប្រើប្រាស់
ដោយពួកគេបានដឹងពីទម្លាប់នៃការញុំារបស់ពួកគាត់ហើយ ប៉ុន្តែបានមើលរំលង។

### ឧទាហរណ៍៤របស់ហ៊ីយ៉ារីហាតុ : ការរាយការណ៍និងការពិគ្រោះយោបល់មិនគ្រប់គ្រាន់

[ព្រឹត្តិការណ៍] ខ្ញុំបានបង្ខំចិត្តធ្វើការទាំងមិនស្រួលខ្លួន ប៉ុន្តែតាមពិតបានឆ្លងជំងឺផ្តាសាយ។

[មូលហេតុ] បុគ្គលិកខ្វះហើយបម្រែបម្រួលការងារគឺវាហាក់ដូចជាគ្មាន ខ្ញុំគិតថាវាមិនមានបញ្ហាប៉ះពាល់ដល់ការងារ
ទើបខ្ញុំមិននិយាយចេញមក។
ការបែកធ្លាយរបាយការណ៍ ការពិគ្រោះយោបល់ដល់បុគ្គលិក

មានករណីជាច្រើនដែលជាបញ្ហាដែលអ្នកមិនបានកត់សម្គាល់ពីហ៊ីយ៉ារីហាតុនៅក្នុងការងារ
ប្រចាំថ្ងៃរបស់អ្នកឬសូម្បីតែអ្នកបានដឹងក៏ដោយ អ្នកមិនអាចចែករំលែកព័ត៌មានបានជាដើម។
ដើម្បីការពារគ្រោះថ្នាក់ធ្ងន់ធ្ងរកើតឡើង សូមធ្វើការរាយការណ៍ឬទាក់ទងទៅបុគ្គលិកថែទាំ
ប្រសិនបើអ្នកកត់សម្គាល់ឬមានកង្វល់ពីរឿងអ្វីមួយ។

ខាងលើនេះជាអ្វីដែលយើងចង់អោយអ្នកគ្រប់គ្នាដែលចង់ក្លាយជាជំនួយការថែទាំដឹងទុកមុន។
សូមសាកល្បង "ការងារដែលអ្នកអាចធ្វើបានដោយខ្លួនឯង" ដោយយកចិត្តទុកដាក់លើចំណុចប្រុងប្រយ័ត្ន។ អ្នកនឹងទទួលបានអារម្មណ៍ជឿជាក់ថាអាចសម្រេចការងារបាន និងរកឃើញអ្វីមួយដែលមានតម្លៃពីការធ្វើការក្នុងនាមជាជំនួយការថែទាំ និងធ្វើការជាមួយបុគ្គលិកថែទាំ។

# ឧបសម្ព័ន្ធ ឯកសារយោងការងារ

## <ឧទាហរណ៍នៃលំហូរក្នុង១ថ្ងៃ>

នៅលើទំព័រនេះ ខ្ញុំនឹងណែនាំជាឧទាហរណ៍អំពីលំហូរការងារប្រចាំថ្ងៃតាមថ្នាក់។
លំហូរការងារផ្លាស់ប្តូរអាស្រ័យលើមណ្ឌលនីមួយៗដូច្នេះសូមប្រើវាជាឯកសារយោង។

| ម៉ោង | ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ការងារស្នូល (បុគ្គលិកថៃទាំ) | ការងារ ទាមទារការយកចិត្តទុកដាក់ (ថ្នាក់A) | ការងារយកចិត្តទុកដាក់ (ថ្នាក់B) | ការងារសាមញ្ញ (ថ្នាក់C) |
|---|---|---|---|---|---|---|
| ពេលព្រឹក | ក្រោកពីគេង | ការរៀបចំពេលក្រោកពីគេង | | | ការរៀបចំបន្ថែមសារធាតុទឹក | បើកវាំងនន |
| | | បង្គន់ | ប្តូរខោទឹកនោម | ហៅប្រាប់ទៅបង្គន់ | | |
| | | ដូរសម្លៀកបំពាក់ | ការប្តូរសម្លៀកនិងរៀបចំអោយស្អាត | | | |
| | អាហារ | អាហារពេលព្រឹក | ជួយបម្លាស់ទីនិងចេញពីគ្រែ | លាយតុរុមី(តុរុមីគឺជាវត្ថុដាក់លាយធ្វើអោយរាវខាប់ៗ) | ចែកចាយឧបករណ៍ជួយស្វ័យ ប្រវត្ត។ល។ | សម្អាតតុ |
| | | | | ហៅប្រាប់ទៅអាហារដ្ឋាន | | ចែកអៀមនិងកន្សែងសើម |
| | | | ជួយពេលបរិភោគអាហារ | មើលថៃទាំ | ការបម្រើនិងលើកទឹកតែ | |
| | | | ចែកថ្នាំ | | | |
| | | | បញ្ជាក់ថ្នាំ ញ៉ាំនិងបរិមាណអាហារ | | រៀបចំសារទុកដាក់ | លាងចាន។ល។ |
| | | | ថៃរក្សាអនាម័យក្នុងមាត់ | | | សម្អាតអាហារដ្ឋាន (សម្អាតតុនិងជាន់ផ្ទាល់ដី) |
| ពេលព្រឹក | សម្អាត | សម្អាតបន្ទប់នៅ | | | | សម្អាតជាន់ផ្ទាល់ដីនិងខ្យល់ចេញចូល |
| | | | | | | លាងបង្គន់ |
| | | | | | | ប្តូរស្រោមពូក |
| | | | | | រៀបចំគ្រែគេង | |
| | | | | | | បោះសម្រាម |
| | | | | | | បំពេញបន្ថែមរបស់ប្រើប្រាស់ |
| | | បោកគក់ | | | | បោកគក់ |
| | | សម្អាតបន្ទប់រួម | | | | សម្អាតជាន់ផ្ទាល់ដីនិងខ្យល់ចេញចូល |
| | | | | | | លាងបង្គន់ |
| | | | | | | ជូតបង្កាន់ដៃ |
| | | | | | | បោសសម្រាម |
| | | | | | | បំពេញបន្ថែមរបស់ប្រើប្រាស់ |
| | ផ្សេងៗ | ការព្យាបាលនីតិសម្បទា | ការអនុវត្តព្យាបាលនីតិសម្បទា | ជួយព្យាបាលដោយធ្វើចលនា | | |
| | | | | ឃ្លាំមើលការបណ្តុះបណ្តាលខ្លួនឯង | | |
| | | | | | | ការរៀបចំ |

| ម៉ោង | ចំណាត់ថ្នាក់ (ធំ) | ចំណាត់ថ្នាក់ (មធ្យម) | ការងារស្នូល (បុគ្គលិកថែទាំ) | ការងារ ទាមទារការយកចិត្តទុកដាក់ (ថ្នាក់A) | ការងារយកចិត្តទុកដាក់ (ថ្នាក់B) | ការងារសាមញ្ញ (ថ្នាក់C) |
|---|---|---|---|---|---|---|
| ពេលថ្ងៃត្រង់ | អាហារ | អាហារថ្ងៃត្រង់ | ជួយម្លាស់ទីនិងចេញពីគ្រែ | លាយតុរម៉ី | ចែកចាយឧបករណ៍ជួយស្វ័យប្រវត្ត | សំអាតតុ |
| | | | | ហៅប្រាប់បម្លាស់ទីទៅអាហារដ្ឋាន | | ចែកអៀមនិងកន្សែងសើម |
| | | | ជួយពេលញ៉ាំអាហារ | មើលថែរក្សា | ការ បម្រើនិងលើកទឹកតែ | |
| | | | ចែកថ្នាំ | | | |
| | | | បញ្ជាក់ថ្នាំញ៉ាំនិងបរិមាណអាហារ | | រៀបចំអីវ៉ាន់ទុកដាក់ | លាងចានឆ្នាំង |
| | | | ថែរក្សាអនាម័យក្នុងមាត់ | | | សម្អាតអាហារដ្ឋាន ( សម្អាតតុនិងជាន់ផ្ទាល់ដី) |
| | ងូតទឹក | រៀបចំត្រៀមអាងងូតទឹក | ជួយបម្លាស់ទី | ហៅប្រាប់ទៅបន្ទប់ទឹក | | ម្តូលក្តៅ |
| | | | | | | រៀបចំសម្លៀកបំពាក់ងូតទឹក |
| | | ងូតទឹក | ដោះខោអាវចេញ | | | |
| | | | ជួយងូតទឹក | មើលថែទាំ | | |
| | | | ស្លៀកខោអាវ | ផ្លុំសក់ | រៀបចំបំពេញបន្ថែមសារធាតុទឹក | សម្អាតបន្ទប់ទឹក |
| | | | | | | បំពេញបន្ថែមរបស់ប្រើប្រាស់ |
| | បោកគក់ | បោកគក់ | | | | បោកគក់បត់ / យកត្រឡប់ទៅទុកវិញ |
| | | | | | | ធ្វើកន្សែងសើម |
| | ការគ្រប់គ្រងថែទាំ | ការគ្រប់គ្រងថែទាំ | | | | លាងរថយន្ត |
| | | | | | | មើលថែដំណាំ(ស្រោចទឹក) |
| | | | | | | ត្រួតពិនិត្យ /បំពេញបន្ថែមឧបករណ៍ |
| | ការកម្សាន្ត | ការកម្សាន្ត | ការជួយដោយផ្ទាល់ | ជំនួយសម្រាប់សកម្មភាពចំណង់ចំណូលចិត្ត | | |
| | | | | គម្រោង | គម្រោង | |
| | | | | | រៀបចំត្រៀម | រៀបចំត្រៀម |
| | | | | ភាពវិវឌ្ឍ /សាស្ត្រាចារ្យ | ភាពវិវឌ្ឍ /សាស្ត្រាចារ្យ | |
| | | | | ជួយគាំទ្រ | | រៀបចំ |
| ពេលល្ងាច/ពេលយប់ | ផ្សេងៗ | ផ្សេងៗ | ការសន្ទនា | ការសន្ទនា | | |
| | | | ជួយចលនាដើរ/ រទេះរុញ | មើលថែទាំពេលបម្លាស់ទីដើរ /រទេះរុញ | | |
| | អាហារ | បាយល្ងាច | ជួយបម្លាស់ទីនិងចេញពីគ្រែ | លាយតុរម៉ី(តុរម៉ីគឺជាវត្ថុដាក់លាយធ្វើអោយរាវខាប់ៗ) | ចែកឧបករណ៍ជួយស្វ័យប្រវត្ត | សម្អាតតុ |
| | | | | ហៅប្រាប់ទៅអាហារដ្ឋាន | | ចែកអៀមនិងកន្សែងសើម |
| | | | ការជួយពេលទទួលទានអាហារ | មើលថែទាំ | ការបម្រើនិងលើកទឹកតែ | |
| | | | ចែកថ្នាំ | | | |
| | | | បញ្ជាក់ពីបរិមាណអាហារនិងថ្នាំ | | រៀបចំទុកដាក់ | លាងចានឆ្នាំង |
| | | | ថែរក្សាអនាម័យក្នុងមាត់ | | | សម្អាតអាហារដ្ឋាន (សម្អាតតុ / ជាន់ផ្ទាល់ដី) |
| | ចូលគេង | បង្គន់ | ជួយពេលទៅបង្គន់ (បង្គន់ / កន្ទប) | ហៅម្ចាស់ទីទៅបង្គន់ | | |
| | | ចូលគេង | ផ្លាស់ប្តូរសម្លៀកបំពាក់ | | | រៀបចំសម្លៀកបំពាក់ប្តូរសម្រាប់ថ្ងៃបន្ទាប់ |
| | | | បញ្ជាក់អំពីការចូលគេង | | | |





ダウンロードはこちらから

http://www.pref.fukuoka.lg.jp/contents/care-supporter.html

発行 福岡県保健医療介護部高齢者地域包括ケア
推進課介護人材確保対策室
制作 公益社団法人福岡県介護老人保健施設協会
編集 株式会社 リベルタス・コンサルティング